# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៥ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការបង្កើតក្រុមប្រឹក្សានីតិកម្ម និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

-តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះចូលមកជំនួសអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្ដីពីការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអាស៊ានចំណុះក្រសួងមហាផ្ទៃ ដែលត្រូវទុកជានិរាករណ៍ ។

Com2/Work/2005

www.pheakdeylaw.com

## ជំពូកទី ២

## ក្រុមប្រឹក្សានីតិកម្ម

**មាត្រា ២.-**

បង្កើតក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃ ដើម្បីជួយរដ្ឋមន្ត្រី ឬសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការកសាងសេចក្តីព្រាងច្បាប់ ឬអនុក្រឹត្យនានាដែលពាក់ព័ន្ធនឹងក្រសួងមហាផ្ទៃ ។

**មាត្រា ៣.-**

សមាសភាពក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃ ត្រូវតែងតាំង និងផ្លាស់ប្តូរដោយអនុក្រឹត្យ តាមការស្នើរបស់រដ្ឋមន្ត្រី ឬសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយធ្វើការជ្រើសរើសក្នុងចំណោមមន្ត្រីជាន់ខ្ពស់នៃក្របខ័ណ្ឌរដ្ឋបាល និងក្របខ័ណ្ឌនគរបាលជាតិក្រសួងមហាផ្ទៃដែលធ្លាប់មានបទពិសោធន៍ខាងការកសាងច្បាប់ ឬមានកម្រិតយល់ដឹងផ្នែកច្បាប់ ។

**មាត្រា ៤.-**

ក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃមានភារកិច្ច ÷

-ពិនិត្យខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ឬអនុក្រឹត្យ និងលិខិតបទដ្ឋាននានា ដែលអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានរដ្ឋបាល ឬអង្គភាពផ្សេងៗចំណុះក្រសួងមហាផ្ទៃ បានតាក់តែងរួចហើយមុននឹងដាក់ឆ្លងមតិថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ

-សិក្សាបំពេញបន្ថែមខ្លឹមសារដែលនៅចន្លោះប្រហោង ឬកាត់បន្ថយខ្លឹមសារណាដែលយល់ឃើញថា មិនសមស្រប

-ស្រាវជ្រាវ និងពិនិត្យខ្លឹមសារនៃសេចក្តីព្រាងច្បាប់ ឬអនុក្រឹត្យ និងលិខិតបទដ្ឋាននានា ធ្វើយ៉ាងណាឱ្យមានលក្ខណៈស្របគ្នាជាមួយប្រព័ន្ធច្បាប់ផ្សេងៗទៀត ដែលបានដាក់ចូលជាធរមានរួចហើយ

-ចាត់ចែងរៀបចំបំពេញបែបបទ ក្នុងការបញ្ជូនសេចក្តីព្រាងច្បាប់ ឬអនុក្រឹត្យនានាទៅរាជរដ្ឋាភិបាល ក្រោយពីមានការសម្រេចពីរដ្ឋមន្ត្រី ឬសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃរួចហើយ

-សិក្សាស្រាវជ្រាវតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋាននានា តាមសំណូមពររបស់រដ្ឋមន្ត្រី ឬសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៥.-**

មន្ត្រីរាជការទាំងអស់ ទាំងក្របខ័ណ្ឌរដ្ឋបាលស៊ីវិល ទាំងក្របខ័ណ្ឌនគរបាលជាតិដែលកំពុងបម្រើការងារនៅក្នុងរចនាសម្ព័ន្ធរបស់ក្រុមអ្នកច្បាប់ ដែលត្រូវតែងតាំងដោយអំណាចនៃអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០០ ត្រូវផ្ទេរបញ្ជូនទៅ ក្នុងអង្គភាពផ្សេងៗ ចំណុះក្រសួងមហាផ្ទៃ តាមការចាំបាច់របស់ខ្លួន ។

**មាត្រា ៦.-**

ក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃ មានប្រធាន ០១ រូប អនុប្រធាន ០១ រូប និងសមាជិកមួយចំនួន តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ប្រធានក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើអនុរដ្ឋលេខាធិការ អនុប្រធានក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើអគ្គនាយករងនៃអគ្គនាយកដ្ឋាន និងសមាជិកក្រុមប្រឹក្សានីតិកម្មគ្រប់រូប មានឋានៈស្មើប្រធាននាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ។

**មាត្រា ៧.-**

សមាជិកក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬរបស់អនុប្រធាន ពេលប្រធានអវត្តមាន និងត្រូវបំពេញការងារផ្សេងទៀត តាមការចាត់តាំងរបស់ប្រធាន។

**មាត្រា ៨.-**

ក្រុមប្រឹក្សានីតិកម្មរបស់ក្រសួងមហាផ្ទៃ មានលេខាធិការដ្ឋានមួយ សម្រាប់ចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ធ្វើកំណត់ហេតុគ្រប់ពេលប្រជុំរបស់ក្រុមប្រឹក្សានីតិកម្ម និងធ្វើកិច្ចការផ្សេងៗទៀត តាមសំណូមពររបស់ក្រុមប្រឹក្សានីតិកម្ម ។

**មាត្រា ៩.-**

លេខាធិការដ្ឋានដឹកនាំដោយប្រធាន ០១ រូប មានឋានៈស្មើប្រធាននាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ និងមានអនុប្រធាន ០១ រូបជាជំនួយ ព្រមទាំងមន្ត្រីមួយចំនួនតាមការចាំបាច់។

## ជំពូកទី៣
## នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ

**មាត្រា ១០.-**

បង្កើតនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ ដែលមានតួនាទីភារកិច្ចដូចខាងក្រោម ÷

-សហការរៀបចំការប្រជុំសិក្ខាសាលា និងពិធីផ្សេងៗជូនថ្នាក់ដឹកនាំក្រសួង

-រៀបចំបែបបទលិខិតឆ្លងដែន ទិដ្ឋាការ និងទម្រង់បែបបទជូនថ្នាក់ដឹកនាំ និងគណៈប្រតិភូ របស់ក្រសួងមហាផ្ទៃ អញ្ជើញទៅបំពេញទស្សនកិច្ចនៅបរទេស

-ទំនាក់ទំនងជាមួយស្ថានទូត និងក្រសួងនានាលើកិច្ចការអន្តរជាតិ

-ចងក្រង និងធ្វើសេចក្តីព្រាងច្បាប់ ព្រមទាំងរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលកម្ពុជា ជាមួយក្រសួងមហាផ្ទៃ នគរបាលជាតិ នៃប្រទេសនានា លើសកលលោក និងបកប្រែលិខិតស្នាមផ្សេងៗ

-ធ្វើទំនាក់ទំនងការងារជាមួយក្រសួងមហាផ្ទៃ និងអគ្គនគរបាលជាតិ នៃប្រទេសនានាលើការងារគ្រប់គ្រងរដ្ឋបាលដែនដី និងការងារនគរបាលជាតិ



www.pheakdeylaw.com

-ស្រាវជ្រាវ និងធ្វើការវិភាគ និងគ្រប់គ្រងការងារអាស៊ាន ដែលទាក់ទិនផ្ទាល់នឹងសមត្ថកិច្ច នៃក្រសួងមហាផ្ទៃ

-ធ្វើលិខិតជូនពរឱ្យថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ក្នុងឱកាសបុណ្យជាតិនិងអន្តរជាតិ

-បូកសរុបការងារ ប្រចាំអឌ្ឍមាស ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ។

**មាត្រា ១១. –**

រចនាសម្ព័ន្ធរបស់នាយកដ្ឋានទំនាក់ទំនងអន្តរជាតិរួមមាន ÷

-ការិយាល័យរដ្ឋបាល និងសរុប

-ការិយាល័យអាស៊ាន

-ការិយាល័យបកប្រែ

-ការិយាល័យអន្តរជាតិ

-ការិយាល័យពិធីការ ។

ការរៀបចំតួនាទីភារកិច្ច និងការប្រព្រឹត្តទៅរបស់ការិយាល័យនីមួយៗ នៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១២. –**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣. –**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល ÷**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

-ដូចមាត្រា១៣

-ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com